# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

របាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ
3 ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021
និង
របាយការណ៍របស់សវនករឯករាជ្យ
ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
សង្ខេបចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | |
| លេខចុះបញ្ជីពាណិជ្ជកម្ម | 00001157 | |
| ទីស្នាក់ការចុះបញ្ជី | អគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង2<br>ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |
| ភាគហ៊ុនិក | Kookmin Bank<br>LOLC International Private Limited<br>The Bank of East Asia, Limited<br>ក្រុមហ៊ុន បុគ្គលិកប្រាសាក់លីមីតធីត | |
| ក្រុមប្រឹក្សាភិបាល | លោក Kwi Sang JUN | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Ji Kyu JANG | សមាជិក |
| | លោក Ishara Chinthaka Nanayakkara | សមាជិក |
| | លោក ស៊ឹម សេនាជាតិ | សមាជិក |
| | លោក Minki Brian HONG | សមាជិក |
| | លោក Hak Soo KIM | សមាជិក (លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2021) |
| គណៈកម្មាធិការប្រតិបត្តិ | លោក ស៊ឹម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ |
| | លោក អ៊ុំ សូផន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ |
| | លោក អ៊ុំ សមអឿន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| | លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>គ្រប់គ្រងអាជីវកម្ម |
| | លោក សាយ សូនី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>គ្រប់គ្រងទីផ្សារ |
| | លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>ធនធានមនុស្ស |
| | លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុក<br>ផែនការ យុទ្ធសាស្ត្រ និងអាជីវកម្ម |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក**

# មាតិកា


| | ទំព័រ |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 6 |
| របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 7 – 8 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 9 |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល | 10 |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 11 |
| របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 12 |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 13 – 52 |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ("ក្រុមប្រឹក្សាភិបាល" ឬ"អភិបាល") នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ("ក្រុមហ៊ុន") សូមធ្វើការបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី31 ខែមីនា ឆ្នាំ2021 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3 ខែ ដែលបានបញ្ចប់។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុនត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 ចុះថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011 និងដែលបានចុះបញ្ជីសារជាថ្មី នាថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលមានសុពលភាព ចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀតក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2011។

ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទូលទំពូង2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពអាជីវកម្មចម្បង

ក្រុមហ៊ុនធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀត ដល់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងនេះ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទ 3 ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល។

## ភាគលាភ

គ្មានការបែងចែកភាគលាភត្រូវបានប្រកាស ឬទូទាត់ក្នុងការិយបរិច្ឆេទទេ ហើយក្រុមប្រឹក្សាភិបាលមិនផ្តល់អនុសាសន៍ឲ្យមានការទូទាត់ភាគលាភ នាកាលបរិច្ឆេទនៃរបាយការណ៍នេះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក | អគារលេខ 212 ផ្លូវ 271 សង្កាត់ទូលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា | ទូរស័ព្ទ៖ 023 220 102 | សេវាអតិថិជន៖ 023 / 086 999 911 | ទូរសារ៖ 023 216 362
ប្រអប់សំបុត្រ៖ 2412 | អ៊ីម៉ែល៖ info@prasac.com.kh | វេបសាយត៍៖ www.prasac.com.kh | ចុះបញ្ជីពាណិជ្ជកម្មលេខ៖ 00001157 | គ្រឹះស្ថានឯកជន

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទានទៅអតិថិជន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបចេញពីបញ្ជីនូវឥណទានអាក្រក់ ត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើឥណទាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃការលុបចេញពីបញ្ជី ទៅលើឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនសម្រាប់ ការខាតបង់ដែលបានរំពឹងទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

### ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមហេតុផលដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្ម ក្រៅពីបំណុលដែលសន្និដ្ឋានថា មិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មទៅតាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន មានភាពពុំត្រឹមត្រូវនោះទេ។

### វិធីសាស្ត្រនៃការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ហើយប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលមិនបានធ្វើសវនកម្មរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការដាក់បញ្ចាំលើទ្រព្យសកម្មណាមួយ របស់ក្រុមហ៊ុនដែលកើតឡើងក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទនោះទេ និង
- ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### បំណុលយថាភាព និងបំណុលផ្សេងៗ (ត)

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងទាមទារឲ្យសងក្នុងអំឡុងពេលមួយឆ្នាំ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ ដែលនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ។

### ការប្រែប្រួលនៃកាលៈទេសៈ

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមាន លក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីការិយបរិច្ឆេទបញ្ចប់ ដល់ការិយបរិច្ឆេទនៃរបាយការណ៍សង្ខេបចន្លោះពេលនេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងកើតមានឡើងមិនប្រក្រតី ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

### ព្រឹត្តិការណ៍បន្តបន្ទាប់

មិនមានព្រឹត្តិការណ៍គួរឲ្យកត់សម្គាល់ណាមួយកើតឡើង ក្រោយកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលតម្រូវឲ្យមានការបង្ហាញ ឬកែតម្រូវ ក្រៅពីអ្វីដែលបានបង្ហាញរួចហើយនៅក្នុងកំណត់សម្គាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក Kwi Sang JUN | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Ji Kyu JANG | អភិបាល |
| លោក Ishara Chinthaka Nanayakkara | អភិបាល |
| លោក ស៊ឹម សេនាជាតិ | អភិបាល |
| លោក Minki Brian HONG | អភិបាល |
| លោក Hak Soo KIM | អភិបាល (លាលែងនៅថ្ងៃទី28 ខែមករា ឆ្នាំ2021) |
| នៅទំនេរ (*) | អភិបាលឯករាជ្យ |
| នៅទំនេរ (*) | អភិបាលឯករាជ្យ |
| នៅទំនេរ (*) | អភិបាលឯករាជ្យ |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ក្រុមប្រឹក្សាភិបាល (ត)

(*): អភិបាលឯករាជ្យទាំងនេះ ត្រូវបានតែងតាំងដោយក្រុមហ៊ុននៅថ្ងៃទី10 ខែមេសា ឆ្នាំ2020 ។ នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ 2020 ក្រុមហ៊ុនបានផ្ញើលិខិតទៅកាន់ ធនាគារជាតិនៃកម្ពុជា ដោយស្នើសុំការអនុម័តលើការតែងតាំងរបស់អភិបាលឯករាជ្យទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ ការស្នើសុំនេះមិនត្រូវបានអនុម័តដោយ ធនាគារជាតិនៃកម្ពុជា ដូចដែលបានរៀបរាប់នៅក្នុងលិខិតចុះថ្ងៃទី28 ខែមករា ឆ្នាំ2021 ។ នៅថ្ងៃទី9 ខែមេសា ឆ្នាំ2021 ក្រុមហ៊ុនបានផ្ញើលិខិតមួយច្បាប់ទៀតទៅកាន់ធនាគារជាតិនៃកម្ពុជា ដោយស្នើសុំការអនុម័តលើការ តែងតាំងបុគ្គលដទៃទៀត រួមមាន លោក Kyung Cheon Lee លោក Jaehong Park និង លោក ចាន់ សុផល ជាអភិបាលឯករាជ្យ។ ក្រុមហ៊ុនកំពុងរង់ចាំការអនុម័តពីធនាគារជាតិនៃកម្ពុជាគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ។

## គណៈគ្រប់គ្រងសំខាន់ៗ

សមាជិកគណៈគ្រប់គ្រងសំខាន់ៗនៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក ស៊ឹម សេនាជាតិ | ប្រធាននាយកប្រតិបត្តិ |
| លោក អ៊ុំ សុជន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកហិរញ្ញវត្ថុ |
| លោក អ៊ុំ សមអឿន | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកប្រតិបត្តិការ |
| លោក នាង សុខឃីម | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងអាជីវកម្ម |
| លោក សាយ សុទី | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងទីផ្សារ |
| លោក ជួប វាសនា | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកធនធានមនុស្ស |
| លោក ជា ហាង | អនុប្រធាននាយកប្រតិបត្តិទទួលបន្ទុកផែនការយុទ្ធសាស្ត្រ និងអាជីវកម្ម |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកនៃក្រុមប្រឹក្សាភិបាលណាម្នាក់ មានភាគកម្មដោយផ្ទាល់ទៅលើមូលធនរបស់ក្រុមហ៊ុនឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងពេល និងនាចុងការិយបរិច្ឆេទបញ្ចប់នេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្នុងនោះក្រុមហ៊ុនជាភាគីម្ខាងអាចបង្កលទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃឡើយ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយលើកលែងតែបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់ក្រុមហ៊ុន នាថ្ងៃទី31 ខែមីនា ឆ្នាំ2021 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3 ខែ ដែលបានបញ្ចប់ ដែលបានបង្ហាញនៅទំព័រទី 9 ដល់ទី 52 ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ គ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ 34 *ការរាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* ("ស.គ.អ.ក 34") ។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយគណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យ សមស្របដែលផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និង ដោយភាពប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។
- អនុលោមតាម តម្រូវការលាតត្រដាងជាចាំបាច់ និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយ CIAS 34 ឬ ប្រសិនបើមានភាពខុសគ្នានៃការអនុវត្តន៍បទបញ្ញត្តិ និងគោលការណ៍ណែនាំ ហើយនឹងស្តង់ដារដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ភាពខុសគ្នាទាំងនោះគួរតែត្រូវបានលាតត្រដាងព័ត៌មានពន្យល់ និងកំណត់បរិមាណក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។
- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថាក្រុមហ៊ុន នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត។
- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់សេចក្តីសម្រេចចិត្ត និងសកម្មភាពទាំងឡាយដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយនឹងត្រូវធានាថាគោលនយោបាយ និងការសម្រេចចិត្តទាំងអស់នោះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

គណៈគ្រប់គ្រង ត្រូវទទួលខុសត្រូវរក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងដើម្បីធានាបានថាបញ្ជីគណនេយ្យត្រូវគោរពតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏ទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាល បានអះអាងថាគណៈគ្រប់គ្រងបានអនុវត្តតាមលក្ខខណ្ឌចាំបាច់នានា ដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

យើងខ្ញុំ បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលត្រូវបានរៀបចំឡើង គ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាម ស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ 34 *ការរាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* ("ស.គ.អ.ក 34")។

*ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។*

លោក ស៊ុម សេនាជាតិ

*អភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 13 ខែឧសភា ឆ្នាំ2021

KPMG

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ជូនចំពោះភាគទុនិករបស់
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក ត្រូវហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែមីនា ឆ្នាំ2021 និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និង របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3 ខែ ដែលបានបញ្ចប់ និងកំណត់សម្គាល់ផ្សេងៗទៀត ដែលបានបង្ហាញនៅទំព័រទី 9 ដល់ទី 52 ហៅកាត់ថា ("របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល")។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា 34 "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ។

### *វិសាលភាពនៃការពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចព្រមព្រៀងត្រួតពិនិត្យលេខ 2410 "ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន"។ ការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល រួមមានការសាកសួរព័ត៌មាន ជាពិសេសសាកសួរបុគ្គលដែលមានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ និងធ្វើការវិភាគ និងនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យ មានទំហំតូចជាងការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ វាមិនអាចឲ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានស្វែងយល់អំពីបញ្ហាជាសារវន្តទាំងអស់ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មបានឡើយ។ ហេតុដូច្នេះយើងខ្ញុំមិនបញ្ចេញមតិសវនកម្មនោះទេ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

KPMG

## *សេចក្តីសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនត្រូវបានរៀបចំជាសារវន្ត ស្របតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា 34 (“របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល”) នោះឡើយ។

## *ការទាញចំណាប់អារម្មណ៍*

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍ទៅលើកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលបង្ហាញពីការរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបដែលបានដាក់បង្ហាញនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020។ សេចក្តីសន្និដ្ឋានរបស់យើងខ្ញុំមិនត្រូវបានកែប្រែដោយសារបញ្ហានេះទេ។

## *បញ្ហាផ្សេងៗ*

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2020 គឺត្រូវបានធ្វើការត្រួតពិនិត្យដោយសវនករឯករាជ្យផ្សេង ដោយបានបញ្ចេញសេចក្តីសន្និដ្ឋានមិនមានបញ្ហានៅថ្ងៃទី7 ខែកញ្ញា ឆ្នាំ2020។ លើសពីនេះទៀត របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ដោយមិនរាប់បញ្ចូលការធ្វើចំណាត់ថ្នាក់ឡើងវិញដូចដែលបានរៀបរាប់នៅក្នុងកំណត់សម្គាល់ 35 នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យផ្សេង ដោយបានបញ្ចេញមតិនៅថ្ងៃទី31 ខែមីនា ឆ្នាំ2021 ថារបាយការណ៍ហិរញ្ញវត្ថុនោះមានភាពត្រឹមត្រូវ។

ជាផ្នែកមួយនៃការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3 ខែដែលបានបញ្ចប់គិតត្រឹមថ្ងៃទី31 ខែមីនា ឆ្នាំ2021 យើងខ្ញុំបានត្រួតពិនិត្យលើការធ្វើចំណាត់ថ្នាក់ឡើងវិញដែលត្រូវបានយកមកអនុវត្តដើម្បីរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ដូចដែលបានរៀបរាប់នៅក្នុងកំណត់សម្គាល់ 35នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។ យើងខ្ញុំមិនត្រូវបានតម្រូវឲធ្វើការត្រួតពិនិត្យឡើងវិញ ឬការប្រើប្រាស់នីតិវិធីណាមួយទៅលើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ក្រៅពីការធ្វើចំណាត់ថ្នាក់ឡើងវិញដែលបានធ្វើការរៀបរាប់នៅក្នុងកំណត់សម្គាល់ 35 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះទេ។ ហេតុដូច្នេះហើយ ជាការសន្និដ្ឋានរបស់យើងខ្ញុំ ការធ្វើចំណាត់ថ្នាក់ឡើងវិញដែលបានរៀបរាប់នៅក្នុងកំណត់សម្គាល់ 35មានភាពត្រឹមត្រូវ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

ព្រះរាជាណាចក្រកម្ពុជា
ខេ ភី អឹម ជី ខេមបូឌា
KPMG CAMBODIA LTD.

**ខៃ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី13 ខែឧសភា ឆ្នាំ2021

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី31 ខែមីនា ឆ្នាំ2021

| | | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|---|
| | *កំណត់សម្គាល់* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក (ការរាយការណ៍ឡើងវិញ)* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4) (ការរាយការណ៍ឡើងវិញ)* |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6 | 189,528,409 | 766,642,414 | 160,578,086 | 649,538,358 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 7 | 353,184,764 | 1,428,632,370 | 438,355,399 | 1,773,147,589 |
| សមតុល្យនៅធនាគារផ្សេងៗ | 8 | 2,462,029 | 9,958,907 | 3,975,029 | 16,078,992 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 3,165,804,794 | 12,805,680,392 | 2,978,579,934 | 12,048,355,833 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 1,723,931 | 6,973,301 | 1,341,096 | 5,424,733 |
| ទ្រព្យ និងបរិក្ខារ | 11 | 5,566,901 | 22,518,115 | 5,662,803 | 22,906,039 |
| សិទ្ធក្នុងការប្រើប្រាស់ទ្រព្យសកម្ម | 12 | 14,633,597 | 59,192,900 | 15,322,179 | 61,978,214 |
| ទ្រព្យសកម្មអរូបី | 13 | 1,578,600 | 6,385,437 | 1,607,168 | 6,500,995 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 20(គ) | 11,728,355 | 47,441,196 | 10,904,851 | 44,110,122 |
| **ទ្រព្យសកម្មសរុប** | | 3,746,211,380 | 15,153,425,032 | 3,616,326,545 | 14,628,040,875 |
| **បំណុលនិងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារ និង ស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | 14 | 56,605,091 | 228,967,593 | 37,232,817 | 150,606,745 |
| ប្រាក់បញ្ញើពីអតិថិជន | 15 | 2,148,797,875 | 8,691,887,404 | 2,074,680,943 | 8,392,084,414 |
| ប្រាក់កម្ចី | 16 | 805,783,059 | 3,259,392,474 | 794,430,317 | 3,213,470,632 |
| មូលបត្របំណុលត្រូវសង | 17 | 31,338,949 | 126,766,049 | 30,666,038 | 124,044,124 |
| អនុបំណុល | 18 | 112,466,761 | 454,928,048 | 113,667,817 | 459,786,320 |
| បំណុលភតិសន្យា | 19 | 13,809,864 | 55,860,900 | 14,424,818 | 58,348,389 |
| បំណុលពន្ធលើប្រាក់ចំណេញ | 20(ខ) | 8,769,054 | 35,470,823 | 24,076,695 | 97,390,231 |
| សំវិធានធនលើអត្ថប្រយោជន៍បុគ្គលិក | 21 | 1,418,199 | 5,736,615 | 435,375 | 1,761,092 |
| បំណុលផ្សេងៗ | 22 | 12,420,349 | 50,240,312 | 7,873,601 | 31,848,716 |
| **បំណុលសរុប** | | 3,191,409,201 | 12,909,250,218 | 3,097,488,421 | 12,529,340,663 |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 23(ក) | 230,000,000 | 920,000,000 | 230,000,000 | 920,000,000 |
| ប្រាក់ចំណេញរក្សាទុក | | 320,512,167 | 1,307,128,354 | 285,224,840 | 1,163,897,093 |
| ទុនបម្រុង | 23(ខ) | 3,166,607 | 12,832,660 | 3,151,952 | 12,773,175 |
| ទុនបម្រុងបទប្បញ្ញត្តិ | 23(គ) | 1,123,405 | 4,465,481 | 461,332 | 1,778,127 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (251,681) | - | 251,817 |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | 554,802,179 | 2,244,174,814 | 518,838,124 | 2,098,700,212 |
| **បំណុលនិងមូលធនម្ចាស់ភាគហ៊ុនសរុប** | | 3,746,211,380 | 15,153,425,032 | 3,616,326,545 | 14,628,040,875 |

*កំណត់សម្គាល់ដែលភ្ជាប់ជាមួយគឺ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។*

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

| | | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2020* | |
|---|---|---|---|---|---|
| | *កំណត់សម្គាល់* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| **ចំណូលប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់ | 24 | 118,818,341 | 482,283,647 | 104,179,358 | 423,384,912 |
| ចំណាយការប្រាក់ | 25 | (50,217,821) | (203,834,136) | (48,396,089) | (196,681,706) |
| **ចំណូលការប្រាក់សុទ្ធ** | | 68,600,520 | 278,449,511 | 55,783,269 | 226,703,206 |
| ចំណូលកម្រៃជើងសារ | 26 | 2,173,850 | 8,823,658 | 1,948,978 | 7,920,647 |
| ចំណាយកម្រៃជើងសារ | | (21,075) | (85,544) | (32,246) | (131,048) |
| **ចំណូលសុទ្ធពីកម្រៃជើងសារ** | | 2,152,775 | 8,738,114 | 1,916,732 | 7,789,599 |
| ចំណូលផ្សេងៗ | 27 | 2,877,695 | 11,680,565 | 2,815,727 | 11,443,116 |
| ចំណូលវិភាគទាន | | 365,210 | 1,482,388 | - | - |
| ចំណេញពីការប្តូររូបិយប័ណ្ណសុទ្ធ | | 641,598 | 2,604,247 | 1,153,910 | 4,689,491 |
| **ចំណូលផ្សេងៗសរុប** | | 3,884,503 | 15,767,200 | 3,969,637 | 16,132,607 |
| **ចំណូលសរុបពី ការប្រាក់ កម្រៃជើងសារនិងចំណូលផ្សេងៗ** | | 74,637,798 | 302,954,825 | 61,669,638 | 250,625,412 |
| ចំណាយលើបុគ្គលិក | 28 | (20,385,032) | (82,742,845) | (18,930,040) | (76,931,683) |
| សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ | 9 | (4,252,318) | (17,260,159) | (6,570,328) | (26,701,813) |
| ចំណាយទូទៅនិងរដ្ឋបាល | 29 | (3,641,347) | (14,780,228) | (3,943,468) | (16,026,252) |
| ចំណាយរំលស់ | 30 | (1,611,500) | (6,541,079) | (1,580,576) | (6,423,461) |
| **ប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | 44,747,601 | 181,630,514 | 30,645,226 | 124,542,203 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(ក) | (8,783,546) | (35,652,414) | (6,162,995) | (25,046,412) |
| **ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | 35,964,055 | 145,978,100 | 24,482,231 | 99,495,791 |
| *ធាតុនៃលទ្ធផលពេញលេញផ្សេងទៀត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (503,498) | - | (1,903,157) |
| **លទ្ធផលពេញលេញសរុប** | | 35,964,055 | 145,474,602 | 24,482,231 | 97,592,634 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយគឺ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

| | *ដើមទុន* | | *ប្រាក់ចំណេញរក្សាទុក* | | *ទុនបម្រុង* | | *ទុនបម្រុងបទប្បញ្ញត្តិ* | | *លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ* | | *សរុប* | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល(កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល(កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល(កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល(កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល(កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល(កំណត់សម្គាល់ 4)* |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 230,000,000 | 920,000,000 | 285,224,840 | 1,163,897,093 | 3,151,952 | 12,773,175 | 461,332 | 1,778,127 | - | 251,817 | 518,838,124 | 2,098,700,212 |
| ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | - | - | 35,964,055 | 145,978,100 | - | - | - | - | - | - | 35,964,055 | 145,978,100 |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (662,073) | (2,687,354) | - | - | 662,073 | 2,687,354 | - | - | - | - |
| ផ្ទេរទៅទុនបម្រុង | - | - | (14,655) | (59,485) | 14,655 | 59,485 | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | (503,498) | - | (503,498) |
| **សមតុល្យនាថ្ងៃទី31 ខែមីនា ឆ្នាំ2021** | 230,000,000 | 920,000,000 | 320,512,167 | 1,307,128,354 | 3,166,607 | 12,832,660 | 1,123,405 | 4,465,481 | - | (251,681) | 554,802,179 | 2,244,174,814 |
| សមតុល្យនាថ្ងៃទី1 ខែមករា ឆ្នាំ2020 (ការរាយការណ៍ឡើងវិញ) | 230,000,000 | 920,000,000 | 174,271,385 | 711,503,244 | 3,093,332 | 12,534,181 | 2,644,420 | 10,715,190 | - | 16,034,618 | 410,009,137 | 1,670,787,233 |
| ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | - | - | 24,482,231 | 99,495,791 | - | - | - | - | - | - | 24,482,231 | 99,495,791 |
| ផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | 2,644,420 | 10,715,190 | - | - | (2,644,420) | (10,715,190) | - | - | - | - |
| ផ្ទេរទៅទុនបម្រុង | - | - | (14,655) | (59,558) | 14,655 | 59,558 | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | (1,903,157) | - | (1,903,157) |
| **សមតុល្យនាថ្ងៃទី31 ខែមីនា ឆ្នាំ2020 (ការរាយការណ៍ឡើងវិញ)** | 230,000,000 | 920,000,000 | 201,383,381 | 821,654,667 | 3,107,987 | 12,593,739 | - | - | - | 14,131,461 | 434,491,368 | 1,768,379,867 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយគឺ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

| | កំណត់សម្គាល់ | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2020* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពប្រតិបត្តិការ** | 31 | (74,229,266) | (301,296,590) | (183,676,845) | (746,462,694) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (409,461) | (1,662,002) | (1,015,789) | (4,128,166) |
| ការទិញទ្រព្យសកម្មអរូបី | | (43,735) | (177,520) | (76,807) | (312,144) |
| សាច់ប្រាក់ពីការលក់ទ្រព្យនិងបរិក្ខារ | | 62,059 | 251,897 | 5,731 | 23,291 |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | (391,137) | (1,587,625) | (1,086,865) | (4,417,019) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីកម្ចី | | 60,244,129 | 244,530,920 | 192,828,010 | 783,653,033 |
| ការទូទាត់ប្រាក់កម្ចី | | (47,940,373) | (194,589,974) | (70,526,799) | (286,620,911) |
| ការទូទាត់អនុបំណុល | | (2,666,667) | (10,824,001) | (2,278,210) | (9,258,645) |
| ការទូទាត់បំណុលភតិសន្យា | | (1,236,280) | (5,018,061) | (1,121,220) | (4,556,638) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាព ហិរញ្ញប្បទាន** | | 8,400,809 | 34,098,884 | 118,901,781 | 483,216,839 |
| **ការថយចុះសុទ្ធនៃសាច់ប្រាក់ និង សាច់ប្រាក់សមមូល** | | (66,219,594) | (268,785,331) | (65,861,929) | (267,662,874) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ | | 417,065,787 | 1,687,031,108 | 430,322,406 | 1,753,563,804 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 927,072 | - | (2,546,789) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | 6 | 350,846,193 | 1,419,172,849 | 364,460,477 | 1,483,354,141 |

កំណត់សម្គាល់ដែលភ្ជាប់ជាមួយគឺ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយ និងត្រូវអានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## 1. ព័ត៌មានអំពីសាជីវកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ 00001157 នាថ្ងៃទី19 ខែកញ្ញា ឆ្នាំ2011។ ក្រុមហ៊ុនបានចុះបញ្ជីសារជាថ្មី នាថ្ងៃទី28 ខែមេសា ឆ្នាំ2016។

ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុឲ្យក្រុមហ៊ុន ដែលមានសុពលភាពចាប់ពីថ្ងៃទី14 ខែធ្នូ ឆ្នាំ2007។ លើសពីនេះទៅទៀតក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ នៅថ្ងៃទី27 ខែសីហា ឆ្នាំ2010 និងការអនុញ្ញាតឲ្យដំណើរការម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ និងសេវាកម្មបង់ប្រាក់តាមម៉ាស៊ីនឆូតកាតនៅថ្ងៃទី01 ខែធ្នូ ឆ្នាំ2011។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មហិរញ្ញវត្ថុដល់សហគមន៍ជនបទ និងសហគ្រាសខ្នាតតូចក្នុងប្រទេសកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ក្រុមហ៊ុន នៅក្នុងរាជធានីភ្នំពេញ និងសាខាជាច្រើននៅក្នុងរាជធានីភ្នំពេញ និងខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា។

ស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ 212 ផ្លូវលេខ 271 សង្កាត់ទួលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី31 ខែមីនា ឆ្នាំ2021 ក្រុមហ៊ុនមានបុគ្គលិកចំនួន 8,904 នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020៖ ចំនួន 9,042នាក់)។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវការរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃ កម្ពុជា ("ស.គ.អ.ក") 34 ("របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល")។ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលមិនបាន រួមបញ្ចូលនូវព័ត៌មានទាំងមូលពេញលេញរបស់របាយការណ៍ហិរញ្ញវត្ថុ ស.រ.ហ.អ.ក។ ទោះជាយ៉ាងណាក្តី កំណត់សម្គាល់ពន្យល់បន្ថែមដែលបានជ្រើសរើសត្រូវបានរួមបញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការទាំងឡាយដែលជាសារវន្តក្នុងការស្វែងយល់ពីការប្រែប្រួលក្នុងរបាយការណ៍ហិរញ្ញវត្ថុ ចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទបញ្ចប់ត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2020។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី13 ខែឧសភា ឆ្នាំ2021។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ខ) រូបិយប័ណ្ណសម្រាប់ការវាស់វែង និងការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារក្រុមហ៊ុន ធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និង កាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត ឬលុះត្រាមានការបង្ហាញផ្សេងពីនោះ។

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធនឹងអនាគត។ តាមនិយមន័យការប៉ាន់ស្មានគណនេយ្យកម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលទាក់ទង។ ដើម្បីលើកកម្ពស់ខ្លឹមសារព័ត៌មាននៃការប៉ាន់ស្មានអថេរសំខាន់ៗមួយចំនួន ដែលត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផល និងក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានធ្វើការសាកល្បងសម្រាប់ភាពប្រែប្រួលទៅនឹងការផ្លាស់ប្តូរនៅក្នុងប៉ារ៉ាម៉ែត្រជាមូលដ្ឋាន។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យជាសារវន្តក្នុងការបង្កឲ្យមានការកែតម្រូវជាសារវន្តទៅនឹងតម្លៃយោងនៃទ្រព្យសម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់មានដូចខាងក្រោម៖

#### *(i) ការវិនិច្ឆ័យ*

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានឥទ្ធិពលជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ដូចខាងក្រោម។

- ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃម៉ូឌែលអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") តាមបរិមាណប្រាក់ដើមដែលនៅជាប់ជំពាក់។

- ការកើនឡើងជាសារវន្តចំពោះហានិភ័យឥណទាន៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ ថាតើ ហានិភ័យឥណទានលើ ទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្រ្តសម្រាប់បញ្ចូលព័ត៌មាននាពេលអនាគតទៅក្នុងការវាស់វែងនៃ ឥណទានដែលរំពឹងថានឹងបាត់បង់ ("ECL") និងការជ្រើសរើស និងការអនុម័តលើម៉ូឌែលដែលប្រើដើម្បីវាស់វែង ECL។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021**

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (គ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

*(ii) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន*

- ឱនភាពនៃតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុៈ កំណត់ការបញ្ចូលសមាសធាតុទៅក្នុងម៉ូឌែលនៃការវាស់វែង ការខាតបង់ឥណទានដែលរំពឹងទុក (ECL) រួមទាំងការបញ្ចូលព័ត៌មាននាពេលអនាគត។
- ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុជាមួយទិន្នន័យមិនអាចអង្កេតបានជាសារវន្ត។
- ការទទួលស្គាល់ និងការវាស់វែងយថាភាពៈ ការសន្មតសំខាន់ៗអំពីលទ្ធភាព និងទំហំនៃលំហូរធនធាន។
- ឱនភាពនៃតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុៈ ការសន្មតសំខាន់ៗ ដែលប្រើក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។

**វីរុសកូវីដ-19 និងផលប៉ះពាល់លើការខាតបង់ឥណទានរំពឹងទុក**

ការខាតបង់ឥណទានរំពឹងទុក ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ច ដែលបានព្យាករណ៍មួយចំនួននៅក្នុងការិយបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃណូវែលវីរុសកូរ៉ូណា ("កូវីដ-19") បានរាលដាលលើប្រទេសចិនដីគោក កម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត ធ្វើឲ្យមានការរាំងស្ទះសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់ទៅលើ GDP និងការ ចង្អុលបង្ហាញសំខាន់ផ្សេងទៀតនឹងត្រូវពិចារណារួមទាំងការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលត្រូវបានប្រើប្រាស់ក្នុងការព្យាករណ៍ការខាតបង់ឥណទានរំពឹងទុក។ អ្នកគ្រប់គ្រងរំពឹងថាអាចមានខាតបង់ឥណទានរំពឹងទុក ដោយផ្អែកទៅលើស្ថានភាពអនាគតដែលអាចកើតឡើង ដោយគិតពីភាពជាក់ស្តែង លក្ខខណ្ឌ និងការព្យាករណ៍នៃស្ថានភាពសេដ្ឋកិច្ចពេលអនាគត និងព័ត៌មានដែលអាចប្រើប្រាស់បាននៅក្នុងការិយបរិច្ឆេទរាយការណ៍។

ការគណនាការខាតបង់ឥណទានរំពឹងទុកនៅស្ថានភាពបច្ចុប្បន្នអាចមានភាពមិនជាក់លាក់ជាសារវន្ត។ អ្នកគ្រប់គ្រងបានព្យាករណ៍ទៅលើផលប៉ះពាល់របស់វីរុសកូវីដ-19ទៅលើក្រុមហ៊ុន ប៉ុន្តែការព្យាករណ៍នេះអាចនឹងប្រែប្រួលជាសារវន្តពេលមានព្រឹត្តិការណ៍ថ្មីៗកើតឡើង។ ជាលទ្ធផល តួលេខនេះគួរតែមិនអាចយកជាការណែនាំជាក់លាក់ ឬការព្យាករណ៍នៃផលប៉ះពាល់ហិរញ្ញវត្ថុចុងក្រោយដែលបានរំពឹងទុកនោះទេ។ នៅពេលដែលផលប៉ះពាល់នោះកាន់តែមានសភាពធ្ងន់ធ្ងរ និងយូរជាងការរំពឹងទុក នោះនឹងបណ្តាលឲ្យមានផលប៉ះពាល់ទៅលើខាតបង់ឥណទានរំពឹងទុក ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021**

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលត្រូវបានយកមកអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺដូចគ្នាទៅនឹងគោលនយោបាយដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 ។

## 4. ការប្តូររូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រា នាកាលបរិច្ឆេទរាយការណ៍។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| | | អត្រានាកាលបរិច្ឆេទរាយការណ៍ | អត្រាមធ្យម |
|---|---|---|---|
| ថ្ងៃទី31 ខែមីនា ឆ្នាំ2021 | 1 ដុល្លារអាមេរិក= | 4,045រៀល | 4,059រៀល |
| ថ្ងៃទី31 ខែមីនា ឆ្នាំ2020 | 1 ដុល្លារអាមេរិក= | 4,070រៀល | 4,064រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | 1 ដុល្លារអាមេរិក= | 4,045រៀល | 4,077រៀល |

តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## 5. បម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្ម

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ជាទូទៅពាក់ព័ន្ធនឹងការផ្តល់សេវាឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗដល់ពលរដ្ឋនិងសហគ្រាស តូច និង មធ្យម និងចូលរួមក្នុងសកម្មភាពផ្សេងទៀតទាំងអស់ ដែលគាំទ្រគោលបំណងទាំងនេះ។ វាពុំមានបច្ច័យដែលនាំឲ្យមានបម្រែបម្រួលតាមរដូវកាលនៃប្រតិបត្តិការអាជីវកម្មជាសារវន្តដែលពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ចទាំងនេះទេ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 6. សាច់ប្រាក់ក្នុងដៃ

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ទីស្នាក់ការកណ្តាល | 40,912,222 | 165,489,938 | 43,578,608 | 176,275,469 |
| សាខានានា | 148,616,187 | 601,152,476 | 116,999,478 | 473,262,889 |
| | 189,528,409 | 766,642,414 | 160,578,086 | 649,538,358 |

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានដូចខាងក្រោម៖

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែមីនា ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| សាច់ប្រាក់ក្នុងដៃ | 189,528,409 | 766,642,414 | 140,077,417 | 570,115,087 |
| *សមតុល្យនៅធនាគារជាតិនៃកម្ពុជា* | | | | |
| គណនីចរន្ត | 78,456,720 | 317,357,432 | 222,063,205 | 903,797,244 |
| គណនីមានកាលកំណត់ (កាលសោន្តដំបូងរហូតដល់3ខែ) | 80,374,166 | 325,113,501 | 223,710 | 910,500 |
| *សមតុល្យនៅធនាគារផ្សេងៗ* | | | | |
| គណនីចរន្ត | 2,423,380 | 9,802,572 | 2,033,264 | 8,275,384 |
| គណនីសន្សំ | 63,518 | 256,930 | 62,881 | 255,926 |
| | 350,846,193 | 1,419,172,849 | 364,460,477 | 1,483,354,141 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 7. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| គណនីចរន្ត | (ក) | 78,456,720 | 317,357,432 | 87,265,227 | 352,987,843 |
| ប្រាក់បញ្ញើមានកាលកំណត់ (កាលវសាន្តដំបូងរហូតដល់ 3ខែ) | (ក) | 80,374,166 | 325,113,501 | 165,207,294 | 668,263,504 |
| ប្រាក់បញ្ញើមានកាលកំណត់ (កាលវសាន្តដំបូងច្រើនជាង 3ខែ) | (ក) | 148,888 | 602,252 | 148,888 | 602,252 |
| ប្រាក់តម្កល់ធានាលើដើមទុន | (ខ) | 23,000,000 | 93,035,000 | 23,000,000 | 93,035,000 |
| ប្រាក់បម្រុងកាតព្វកិច្ច | (គ) | 171,204,990 | 692,524,185 | 162,733,990 | 658,258,990 |
| | | 353,184,764 | 1,428,632,370 | 438,355,399 | 1,773,147,589 |

### (ក) គណនីចរន្ត និងប្រាក់បញ្ញើមានកាលកំណត់

គណនីចរន្តមិនទទួលបានការប្រាក់នោះទេ។

ប្រាក់បញ្ញើនេះអាចមានកាលកំណត់រហូតដល់ 3ខែ ត្រូវទទួលបានការប្រាក់ប្រចាំឆ្នាំចាប់ពី 0.02% ទៅ 1.55% (ឆ្នាំ 2020៖ ចាប់ពី 0.02% ដល់ 1.60%) ហើយលើសពី 3ខែ នឹងទទួលបានអត្រាប្រចាំឆ្នាំរហូតដល់ 0.23% ទៅ 1.93% (ឆ្នាំ 2020៖ ចាប់ពី 0.23% ដល់ 1.93%)។

### (ខ) ប្រាក់តម្កល់ធានាលើដើមទុន

តាមប្រកាសលេខ B7-07-163 ចុះថ្ងៃទី13 ខែធ្នូ ឆ្នាំ2007 ស្តីអំពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ក្រុមហ៊ុនតម្រូវឲ្យរក្សាប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 10% នៃដើមទុនចុះបញ្ជីជាមួយធនាគារជាតិនៃកម្ពុជា។ ប្រាក់បញ្ញើនេះ មិនអាចយកសម្រាប់ការប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុននោះទេ ប៉ុន្តែត្រូវបានបង្វិលសងវិញនៅពេលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់អាជីវកម្មនៅក្នុងប្រទេសកម្ពុជា។ ប្រាក់តម្កល់ធានាលើដើមទុនទទួលបានការប្រាក់ប្រចាំឆ្នាំចំនួន 0.06% នៅក្នុងការិយបរិច្ឆេទ (ឆ្នាំ 2020៖ 0.09%)។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021**

## 7. សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ត)

### (គ) ប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ច គឺជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលត្រូវបានគណនាតាមអត្រា 8.00% នៃប្រាក់បញ្ញើរបស់អតិថិជន ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ B7-07-163។ ប្រាក់បម្រុងកាតព្វកិច្ច តម្រូវឲ្យមានការបត់បែនដោយផ្អែកលើកម្រិតនៃការដាក់ប្រាក់បញ្ញើពីអតិថិជន ហើយប្រាក់បម្រុងកាតព្វកិច្ចពុំទទួលបានការប្រាក់នោះទេ។

## 8. សមតុល្យនៅធនាគារផ្សេងៗ

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| គណនីចរន្ត | 2,423,380 | 9,802,572 | 3,959,939 | 16,017,953 |
| គណនីសន្សំ | 63,518 | 256,930 | 55,241 | 223,450 |
| សមតុល្យដុលជាមួយធនាគារផ្សេងៗ | 2,486,898 | 10,059,502 | 4,015,180 | 16,241,403 |
| សំវិធានធនលើឱនភាពនៃតម្លៃ | (24,869) | (100,595) | (40,151) | (162,411) |
| | 2,462,029 | 9,958,907 | 3,975,029 | 16,078,992 |

គណនីចរន្ត ទទួលបានការប្រាក់រហូតដល់ 0.75% (ឆ្នាំ2020៖ 0.00% ទៅ 1.00%)។ គណនីសន្សំទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 0.00% ទៅ 0.15% ក្នុងការិយបរិច្ឆេទ (ឆ្នាំ2020៖ 0.00% ទៅ 1.00%)។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 9. ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជនដែលត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | | | |
|---|---|---|---|---|---|
| | *ដំណាក់កាលទី 1* | *ដំណាក់កាលទី 2* | *ដំណាក់កាលទី 3* | *សរុប* | |
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ឥណទានបុគ្គល | 3,069,527,942 | 50,940,278 | 43,090,924 | 3,163,559,144 | 12,796,596,737 |
| ឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម | 46,875,994 | 1,434,156 | 1,555,115 | 49,865,265 | 201,704,997 |
| ឥណទានបុគ្គលិក | 8,436,899 | 4,159 | 23,424 | 8,464,482 | 34,238,830 |
| ឥណទានក្រុម | 264,498 | 5,375 | 17,779 | 287,652 | 1,163,552 |
| | 3,125,105,333 | 52,383,968 | 44,687,242 | 3,222,176,543 | 13,033,704,116 |
| កម្រៃពីឥណទានដែលមិនទាន់ទទួលស្គាល់ | (3,912,677) | (26,753,386) | (200,004) | (30,866,067) | (124,853,241) |
| | 3,121,192,656 | 25,630,582 | 44,487,238 | 3,191,310,476 | 12,908,850,875 |
| ការប្រាក់បង្គរត្រូវទទួល | 3,744,925 | 24,329,481 | 300,661 | 28,375,067 | 114,777,146 |
| | 3,124,937,581 | 49,960,063 | 44,787,899 | 3,219,685,543 | 13,023,628,021 |
| សំវិធានធនលើឱនភាពនៃតម្លៃ | (13,007,585) | (13,188,788) | (27,684,376) | (53,880,749) | (217,947,629) |
| | 3,111,929,996 | 36,771,275 | 17,103,523 | 3,165,804,794 | 12,805,680,392 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | | | | |
|---|---|---|---|---|---|
| | ដំណាក់កាលទី 1 | ដំណាក់កាលទី 2 | ដំណាក់កាលទី 3 | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ឥណទានបុគ្គល | 2,883,452,590 | 50,137,301 | 39,973,285 | 2,973,563,176 | 12,028,063,047 |
| ឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម | 45,660,603 | 1,542,633 | 1,530,383 | 48,733,619 | 197,127,489 |
| ឥណទានបុគ្គលិក | 8,124,752 | - | 23,603 | 8,148,355 | 32,960,096 |
| ឥណទានក្រុម | 353,871 | 7,252 | 14,456 | 375,579 | 1,519,217 |
| | 2,937,591,816 | 51,687,186 | 41,541,727 | 3,030,820,729 | 12,259,669,849 |
| កម្រៃពីឥណទានដែលមិនទាន់ទទួលស្គាល់ | (3,643,425) | (269,408) | (24,945,958) | (28,858,791) | (116,733,810) |
| | 2,933,948,391 | 51,417,778 | 16,595,769 | 3,001,961,938 | 12,142,936,039 |
| ការប្រាក់បង្គរត្រូវទទួល | 22,771,402 | 544,924 | 2,915,163 | 26,231,489 | 106,106,373 |
| | 2,956,719,793 | 51,962,702 | 19,510,932 | 3,028,193,427 | 12,249,042,412 |
| សំវិធានធនលើឱនភាពនៃតម្លៃ | (11,262,106) | (12,954,251) | (25,397,136) | (49,613,493) | (200,686,579) |
| | 2,945,457,687 | 39,008,451 | (5,886,204) | 2,978,579,934 | 12,048,355,833 |

ក្នុងអំឡុងការិយបរិច្ឆេទ ក្រុមហ៊ុនបានទទួលស្គាល់សំវិធានធនលើ ឥណទានផ្តល់ដល់អតិថិជន សមតុល្យនៅធនាគារផ្សេង និងទ្រព្យសកម្មផ្សេងៗ ដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនាឆ្នាំ2021 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនាឆ្នាំ 2020 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| ឥណទានផ្តល់ដល់អតិថិជន | 4,267,256 | 17,320,794 | 6,559,584 | 26,658,149 |
| បញ្ញើពីអតិថិជន និងគ្រឹះស្ថានធនាគារ | (15,282) | (62,029) | 10,137 | 41,197 |
| ប្រាក់ត្រូវទទួលបានផ្សេងៗ | 344 | 1,394 | 607 | 2,467 |
| | 4,252,318 | 17,260,159 | 6,570,328 | 26,701,813 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

បម្រែបម្រួលសំវិធានធនលើឱនភាពនៃតម្លៃមានក្នុងដូចខាងក្រោម៖

| | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| សមតុល្យដើមគ្រា | 49,613,493 | 200,686,579 | 26,232,892 | 106,899,034 |
| សំវិធានធនលើឱនភាពនៃតម្លៃក្នុង | | | | |
| អំឡុងការិយបរិច្ឆេទ | 4,267,256 | 17,320,794 | 6,559,584 | 26,658,149 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (59,744) | - | (91,806) |
| សមតុល្យចុងគ្រា | 53,880,749 | 217,947,629 | 32,792,476 | 133,465,377 |

ការវិភាគបន្ថែមនៃឥណទានផ្តល់ដល់អតិថិជនត្រូវបានកំណត់ដូចខាងក្រោម៖

(ក) តាមទ្រព្យធានា

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| មានវត្ថុបញ្ចាំ | | | | |
| អចលនទ្រព្យ | 199,757,815 | 808,020,362 | 178,699,933 | 722,841,229 |
| ចលនវត្ថុ | 133,165,884 | 538,656,001 | 124,214,580 | 502,447,976 |
| តម្កល់ប្រាក់ទុក | 880,012 | 3,559,649 | 637,871 | 2,580,188 |
| ផ្សេងៗ | 1,032,461,579 | 4,176,307,087 | 962,522,312 | 3,893,402,752 |
| ពុំមានវត្ថុបញ្ចាំ | | | | |
| អចលនទ្រព្យ | 262,940,620 | 1,063,594,808 | 242,894,844 | 982,509,644 |
| ចលនវត្ថុ | 162,462,694 | 657,161,597 | 157,008,498 | 635,099,374 |
| ផ្សេងៗ | 1,428,016,939 | 5,776,328,517 | 1,362,215,389 | 5,510,161,249 |
| | 3,219,685,543 | 13,023,628,021 | 3,028,193,427 | 12,249,042,412 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

ការវិភាគបន្ថែមនៃឥណទានផ្តល់ដល់អតិថិជនត្រូវបានកំណត់ដូចខាងក្រោម៖ (ត)

(ខ) តាមកាលកំណត់

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ក្នុងរយៈពេល 1ខែ | 97,783,793 | 395,535,443 | 91,934,370 | 371,874,527 |
| ច្រើនជាង 1ខែ ដល់ 3ខែ | 123,885,433 | 501,116,576 | 128,446,764 | 519,567,160 |
| ច្រើនជាង 3ខែ ដល់ 12ខែ | 561,963,038 | 2,273,140,489 | 541,923,856 | 2,192,081,998 |
| ច្រើនជាង 1ឆ្នាំ ដល់ 5ឆ្នាំ | 2,038,145,886 | 8,244,300,109 | 1,935,325,429 | 7,828,391,360 |
| ច្រើនជាង 5ឆ្នាំ | 397,907,393 | 1,609,535,404 | 330,563,008 | 1,337,127,367 |
| | 3,219,685,543 | 13,023,628,021 | 3,028,193,427 | 12,249,042,412 |

(គ) តាមនិវាសនភាព ទំនាក់ទំនង រូបិយប័ណ្ណ និងវិស័យឧស្សាហកម្ម

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ***និវាសនភាព*** | | | | |
| និវាសនជន | 3,219,685,543 | 13,023,628,021 | 3,028,193,427 | 12,249,042,412 |
| ***ទំនាក់ទំនង*** | | | | |
| អតិថិជនខាងក្រៅ | 3,211,224,911 | 12,989,404,765 | 3,020,051,028 | 12,216,106,408 |
| ឥណទានបុគ្គលិក | 8,460,632 | 34,223,256 | 8,142,399 | 32,936,004 |
| | 3,219,685,543 | 13,023,628,021 | 3,028,193,427 | 12,249,042,412 |
| ***រូបិយប័ណ្ណ*** | | | | |
| ដុល្លារអាមេរិក | 2,813,436,512 | 11,380,350,691 | 2,638,558,932 | 10,672,970,880 |
| រៀល | 388,404,816 | 1,571,097,480 | 365,326,565 | 1,477,745,955 |
| បាតថៃ | 17,844,215 | 72,179,850 | 24,307,930 | 98,325,577 |
| | 3,219,685,543 | 13,023,628,021 | 3,028,193,427 | 12,249,042,412 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 9. ឥណទានផ្តល់ដល់អតិថិជន (ត)

(គ) តាមនិវាសនភាព ទំនាក់ទំនង រូបិយប័ណ្ណ និងវិស័យឧស្សាហកម្ម (ត)

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| *វិស័យឧស្សាហកម្ម* | | | | |
| ពាណិជ្ជកម្ម និងជំនួញ | 797,340,306 | 3,225,241,538 | 745,402,429 | 3,015,152,826 |
| សេវាកម្ម | 545,881,757 | 2,208,091,707 | 513,552,045 | 2,077,318,022 |
| អចលនទ្រព្យ | 462,698,435 | 1,871,615,170 | 421,594,777 | 1,705,350,873 |
| កសិកម្ម | 406,994,664 | 1,646,293,416 | 408,192,523 | 1,651,138,756 |
| កែលម្អគេហដ្ឋាន | 385,036,186 | 1,557,471,372 | 346,941,003 | 1,403,376,357 |
| យានយន្ត | 295,628,578 | 1,195,817,598 | 281,223,077 | 1,137,547,346 |
| ការដឹកជញ្ជូន | 231,418,918 | 936,089,523 | 221,905,561 | 897,607,994 |
| ផលិតកម្ម | 36,637,856 | 148,200,128 | 34,613,559 | 140,011,846 |
| សំណង់ | 31,919,868 | 129,115,866 | 29,420,267 | 119,004,980 |
| ប្រើប្រាស់ផ្ទាល់ខ្លួន | 26,128,975 | 105,691,703 | 25,348,186 | 102,533,412 |
| | 3,219,685,543 | 13,023,628,021 | 3,028,193,427 | 12,249,042,412 |

## 10. ទ្រព្យសកម្មផ្សេងៗ

| | *ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | *ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ 4)* |
| ប្រាក់បង់មុន | 1,119,456 | 4,528,200 | 767,359 | 3,103,967 |
| ប្រាក់តម្កល់ | 533,063 | 2,156,240 | 513,266 | 2,076,161 |
| ការវិនិយោគរយៈពេលវែង | 28,167 | 113,936 | 28,167 | 113,936 |
| ផ្សេងៗ | 53,906 | 218,049 | 42,604 | 172,333 |
| | 1,734,592 | 7,016,425 | 1,351,396 | 5,466,397 |
| សំវិធានធនលើឱនភាពនៃតម្លៃ | (10,661) | (43,124) | (10,300) | (41,664) |
| | 1,723,931 | 6,973,301 | 1,341,096 | 5,424,733 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021

## 11. ទ្រព្យ និងបរិក្ខារ

| | *សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែមីនា ឆ្នាំ2021* | | | | | | | |
|---|---|---|---|---|---|---|---|---|
| | *គ្រឿងសង្ហារឹម* | *យានយន្ត* | *ទោចក្រយានយន្ត* | *កុំព្យូទ័រ និងបរិក្ខារ បច្ចេកវិទ្យា* | *ការកែលម្អអគារ* | *បរិក្ខារទំនាក់ទំនង* | *ការងារកំពុង ដំណើរការ* | *សរុប* |
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ថ្លៃដើម** | | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 5,355,637 | 3,037,394 | 360,678 | 9,030,420 | 2,401,455 | 326,356 | 295,714 | 20,807,654 |
| ទិញបន្ថែម | 58,068 | 97,500 | - | 100,272 | 3,090 | 1,505 | 149,026 | 409,461 |
